**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

**សំណុំរឿងលេខ:** ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ)

**ភាគីដាក់ឯកសារ:** សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី
សំ សុគង់
Emmanuel JACOMY
Lyma NGUYEN

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 31-Oct-2017, 08:00
CMS/CFO: Sann Rada

**ដាក់ជូន:** អង្គបុរេជំនុំជម្រះ

**ភាសាដើម:** អង់គ្លេស

**កាលបរិច្ឆេទឯកសារ:** ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៧

**ចំណាត់ថ្នាក់ឯកសារ**

**ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ:** សាធារណៈ

**ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ:** សម្ងាត់

**ចំណាត់ថ្នាក់ប្រភេទឯកសារ:**

**ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:**

**ឈ្មោះមន្ត្រីកត់ត្រា:**

**ហត្ថលេខា:**

---

# សារណារបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអំពីជំហររបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា

---

**ដាក់ដោយ÷**

**សហមេធាវី÷**

សំ សុគង់
Emmanuel JACOMY
Lyma NGUYEN

**ផ្ញើជូន÷**

**សហចៅក្រមស៊ើបអង្កេត÷**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម Olivier BEAUVALLET

ចៅក្រម ន៍យ ថុល

ចៅក្រម BAIK Kang Jin

ចៅក្រម ហួត វុទ្ធី

**សហព្រះរាជអាជ្ញា÷**

ជា លាង
Nicholas KOUMJIAN

**សហព្រះរាជអាជ្ញា÷**

**សហមេធាវីការពារក្តី អ៊ឹម ចែម÷**

ប៊ិត សាងលីម
Wayne JORDASH
Nicholas KOUMJIAN

**មេធាវីតំណាងដើមដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង ០០៤/១**

D308/3/1/9

សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមដាក់ដោយក្តីគោរពដល់អង្គបុរេជំនុំជម្រះនូវ*សារណារបស់ខ្លួនស្តីពីជំហររបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា*។

1.

## ប្រវត្តិនៃដំណើរការនីតិវិធី

2. នៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេត បានចេញផ្នែកសម្រេចសេចក្តីនៃដីកាដំណោះស្រាយរបស់ខ្លួន ដោយច្រានចោលរាល់ការចោទប្រកាន់ទាំងអស់ប្រឆាំងនឹង អ៊ឹម ចែម ក្នុងសំណុំរឿង ០០៤/១[1]។ នៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ (សំអាងហេតុ) ("ដីកាដំណោះស្រាយ")[2] ដែលសហព្រះរាជអាជ្ញាអន្តរជាតិបានបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកានេះ នៅថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០១៧[3]។ នៅថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៧ សហមេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់សំណើសុំការពន្យារពេល និងសុំការអនុញ្ញាត ដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ("សំណើ")[4]។ នៅថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៧ សហមេធាវីការពារក្តីរបស់ អ៊ឹម ចែម បានដាក់ចម្លើយតបទៅនឹងសំណើនេះ[5] ហើយនៅថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៧ សហមេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី[6] និងសហព្រះរាជអាជ្ញាអន្តរជាតិ[7]

---

[1] ឯកសារ D308, ដីកាដំណោះស្រាយ (ផ្នែកសេចក្តីសម្រេច) ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៧។

[2] ឯកសារ D308/3, ដីកាដំណោះស្រាយ (សំអាងហេតុ) ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧។

[3] ឯកសារ D308/3/1/1, បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០១៧។

[4] ឯកសារ D308/3/1/4, សំណើរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិ សុំពន្យារពេល និងសុំការអនុញ្ញាតដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ជាភាសាអង់គ្លេសសិន ដោយសំណៅជាភាសាខ្មែរនឹងដាក់តាមក្រោយ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៧។

[5] ឯកសារ D308/3/1/5, ចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងសំណើរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិ សុំពន្យារពេល និងសុំការអនុញ្ញាតដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដំណោះស្រាយមានសំអាងហេតុ ជាភាសាអង់គ្លេសមុនសិន ដោយសំណៅជាភាសាខ្មែរនឹងដាក់តាមក្រោយ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៧។

[6] ឯកសារ D308/3/1/6, ការឆ្លើយតបរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិ ទៅនឹងចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងសំណើរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិ សុំពន្យារពេល និងសុំការអនុញ្ញាតដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍

D308/3/1/9

បានដាក់ការឆ្លើយតបរបស់ខ្លួន។ នៅថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៧ អង្គបុរេជំនុំជម្រះបាន បដិសេធសំណើនោះ ប៉ុន្តែបានស្នើសហមេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីឱ្យដាក់ សារណា នៅចំពោះមុខអង្គបុរេជំនុំជម្រះ អំពីបញ្ហាពាក់ព័ន្ធនឹងជំហររបស់ អ.វ.ត.ក នៅក្នុង ប្រព័ន្ធច្បាប់កម្ពុជា នៅត្រឹមថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៧ ជាភាសាអង់គ្លេសមុន ដោយឯកសារ បកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយឱ្យលឿនបំផុតតាមដែលអាចធ្វើទៅបាន[8]។

## សារណា

3. នៅមុនពេលលើកសំអាងហេតុលើយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក លើ អ៊ឹម ចែម ដីកាដំណោះស្រាយពិភាក្សាអំពី*ជំហររបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា៖ យុត្តាធិការបុគ្គល យុត្តាធិការពេលវេលា និងយុត្តាធិការបទល្មើស* (ផ្នែក ២.១.១)។ នៅក្នុងផ្នែកនេះ ដីកាដំណោះស្រាយសន្និដ្ឋានថា អានុភាពមួយក្នុងចំណោមអានុភាពនានានៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក គឺខ្លួន "មិនរាប់បញ្ចូលយុត្តាធិការបុគ្គល ឬយុត្តាធិការបទល្មើសរបស់តុលាការកម្ពុជាធម្មតា ទៅលើព្រឹត្តិការណ៍នានា ដែលស្ថិតនៅក្នុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ឡើយ"[9]។ ដូច្នេះ ដីកាដំណោះស្រាយអះអាងថានឹងដកចេញតាមផ្លូវច្បាប់នូវយុត្តាធិការរបស់តុលាការកម្ពុជាធម្មតា ដែលវិនិច្ឆ័យលើឧក្រិដ្ឋកម្ម*ណាមួយ*ក្នុងសម័យខ្មែរក្រហម រួមទាំងឧក្រិដ្ឋកម្មទាំងឡាយណា ដែលស្ថិតនៅក្រៅយុត្តាធិការដែលមានកម្រិតរបស់ អ.វ.ត.ក ផង។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើដោយក្តីគោរពដល់អង្គបុរេជំនុំជម្រះ កែតម្រូវសំអាងហេតុដែលមានការភាន់ច្រឡំក្នុងដីកាដំណោះស្រាយ លើយុត្តាធិការនៃតុលាការកម្ពុជាសាមញ្ញ ដោយហេតុថា៖ (i) សំអាងហេតុទាំងនោះគ្មានយុត្តិកម្ម ពុំមានភាពស៊ីចង្វាក់គ្នា និងអាចធ្វើឱ្យប៉ះ ពាល់

---

របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដំណោះស្រាយមានសំអាងហេតុ ជាភាសាអង់គ្លេសមុនសិន ដោយសំណៅជាភាសាខ្មែរនឹងដាក់តាមក្រោយ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៧។

[7] ឯកសារ D308/3/1/7 ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងសំណើសុំរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៧។

[8] ឯកសារ D308/3/1/8, សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ សំណើរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាតិពាក់ព័ន្ធនឹងការដាក់ចម្លើយទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ និងការអញ្ជើញឱ្យដាក់សារណា។ ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៧។ ដោយសារសារៈសំខាន់នៃបញ្ហាចំពោះដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី Emmanuel JACOMY និង Lyma Nguyen ក៏បានចូលរួមក្នុងសារណាបច្ចុប្បន្នផងដែរ។

[9] ឯកសារ D308/3, ដីកាដំណោះស្រាយ (សំអាងហេតុ), ថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០១៧ កថាខណ្ឌ ២៣។

D308/3/1/9

យ៉ាងខ្លាំងដល់ផលប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី រួមទាំងមរតកផ្ទាល់របស់ អ.វ.ត.ក និង (ii) សំអាងហេតុទាំងនោះបំពានលើច្បាប់អន្តរជាតិ និងច្បាប់កម្ពុជា។

**I. សំអាងហេតុលើយុត្តាធិការក្នុងដីកាដំណោះស្រាយ គ្មានយុត្តិកម្ម ពុំមានភាពស៊ីចង្វាក់គ្នា និងប៉ះពាល់យ៉ាងខ្លាំងដល់ផលប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី រួមទាំងមរតករបស់ អ.វ.ត.ក បើសិនជាគ្មានការដោះស្រាយពីអង្គបុរេជំនុំជម្រះនោះទេ**

4. ជាចំណុចដំបូងនៃបញ្ហាត្រូវដោះស្រាយ ដីកាដំណោះស្រាយជាទ្រឹស្ដីមិនចាំបាច់បញ្ជាក់ថាតើតុលាការកម្ពុជាសាមញ្ញ អាចអនុវត្តយុត្តាធិការលើឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហម ដែលត្រូវបានប្រព្រឹត្តដោយបុគ្គលម្នាក់ៗ ក្រៅតែនៅចំពោះមុខ អ.វ.ត.ក បានដែរ ឬអត់នោះទេ។ សំអាងហេតុទូលំទូលាយក្នុងដីកាដំណោះស្រាយលើយុត្តាធិការនៃតុលាការកម្ពុជាសាមញ្ញ គឺពុំចាំបាច់ខ្លាំងណាស់ណានោះទេ ក្នុងការកំណត់ថាតើ អ៊ឹម ចែម ស្ថិតនៅក្នុងយុត្តាធិការបុគ្គលដែលមានកម្រិតរបស់ អ.វ.ត.ក ឬអត់នោះទេ។ សំអាងហេតុទាំងនេះក៏ចេញហួសយ៉ាងឆ្ងាយពីអាណត្តិរបស់ អ.វ.ត.ក ផងដែរ។ យុត្តាធិការនៃតុលាការកម្ពុជា គឺជាបញ្ហាមួយដែលត្រូវកំណត់ដោយតុលាការកម្ពុជាខ្លួនឯងផ្ទាល់ មិនមែនដោយ អ.វ.ត.ក នោះទេ។ ខណៈដែលអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក បានទទួលស្គាល់ថា "គ្មានបន្ទាត់ខណ្ឌចែកអំណាចរវាង អ.វ.ត.ក និងតុលាការជាតិនោះទេ"[10] ដីកាដំណោះស្រាយជាសំខាន់ខិតខំដកយុត្តាធិការចេញពីតុលាការកម្ពុជាធម្មតា តាមរយៈសិទ្ធិអំណាចតុលាការ។

5. លើសពីនេះទៀត សំអាងហេតុក្នុងដីកាដំណោះស្រាយលើយុត្តាធិការនៃតុលាការកម្ពុជាសាមញ្ញ គឺពុំមានភាពស៊ីចង្វាក់គ្នាដោយផ្ទាល់តែម្ដង។ ដីកាដំណោះនេះស្រាយចាប់ផ្ដើមពិភាក្សាដោយធ្វើការកត់សម្គាល់ថា ភាពផ្ដាច់មុខនៃយុត្តាធិការរបស់ អ.វ.ត.ក ពង្រីកដល់បុគ្គល ឬព្រឹត្តិការណ៍

---

[10] សំណុំរឿងលេខ ០០១/ ១៨ កក្កដា ២០០៧/អវតក/អជសង ឯកសារ E39/5, សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើសុំដោះលែងជនជាប់ចោទឲ្យនៅក្រៅឃុំ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៩ កថាខណ្ឌ ១៣។ *សូមមើល* សំណុំរឿងលេខ ០០១/១៨ កក្កដា ២០០៧-អវតក/អជសង (អ.ប.ជ) ឯកសារ C5/45, សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្ដោះអាសន្នរបស់ជនត្រូវចោទ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០០៧ កថាខណ្ឌ ១៩ ("ក្នុងការអនុវត្តជាក់ស្ដែង និងតាមផ្លូវច្បាប់ អ.វ.ត.ក គឺជាស្ថាប័នឯករាជ្យ ហើយដំណើរប្រតិបត្តិការរបស់ខ្លួនក៏ឯករាជ្យនៅក្នុងរចនាសម្ព័ន្ធតុលាការជាតិ *ដូច្នេះ អ.វ.ត.ក គ្មានសមត្ថកិច្ច វិនិច្ឆ័យលើចំណាត់ការរបស់ស្ថាប័នតុលាការផ្សេងឡើយ*") (មានការបញ្ជាក់បន្ថែម)។

D308/3/1/9

ដែល "ស្ថិតនៅក្នុងយុត្តាធិការបុគ្គល យុត្តាធិការពេលវេលា *និង*យុត្តាធិការបទល្មើសរបស់ អ.វ.ត.ក"[11]។ យោងតាមអត្ថន័យធម្មតានៃភាសានេះ តុលាការកម្ពុជាសាមញ្ញអាចនឹងត្រូវបានរារាំងមិនឲ្យអនុវត្តយុត្តាធិការលើសំណុំរឿងណា ដែលស្ថិតក្នុងយុត្តាធិការមានកម្រិតរបស់ អ.វ.ត.ក បើទោះជាតុលាការទាំងនេះនៅតែមានសក្តានុពលវិនិច្ឆ័យសំណុំរឿង ក្នុងសម័យខ្មែរក្រហមផ្សេងៗទៀត ក្នុងនោះរួមទាំងបទល្មើសប្រឆាំងនឹងចារីដែលមិនមែនជាមេដឹកនាំជាន់ខ្ពស់ ហើយក៏មិនមែនជាជនទទួលខុសត្រូវខ្ពស់បំផុតក្តី។ គោលការណ៍ស្រដៀងគ្នាមួយត្រូវបានឆ្លុះបញ្ចាំងនៅក្នុងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដោយសំអាងលើដីកាដំណោះស្រាយក្នុងផ្នែក ២.១.១[12] ដែលមានជាអាទិ៍ដូចជា អ.វ.ត.ក ត្រូវបាន "ផ្តល់" នូវវិសាលភាពមានកម្រិតនៃភាពផ្តាច់មុខលើយុត្តាធិការ ក្នុងអំឡុងពេលប្រតិបត្តិការរបស់ខ្លួនលើការកាត់ទោសមេដឹកនាំជាន់ខ្ពស់ និងជនដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហម[13]។

6. ទោះបីជាមានការប្រើប្រាស់គោលការណ៍នេះក្តី ក៏ដីកាដំណោះស្រាយក្រោយមកបានពង្រីកវិសាលភាពរបស់ខ្លួនយ៉ាងខ្លាំង ដោយសន្និដ្ឋានថា ច្បាប់ អ.វ.ត.ក "មិនរាប់បញ្ចូល

---

[11] ឯកសារ D308/3, ដីកាដំណោះស្រាយ (សំអាងហេតុ), ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ កថាខណ្ឌ ១២(មានការបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ ផ្នែកចំណងជើងត្រង់ផ្នែក ២.១.១*(ក្រោមចំណងជើង "ជំហររបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា៖ យុត្តាធិការបុគ្គល យុត្តាធិការពេលវេលា និងយុត្តាធិការបទល្មើស)។

[12] ឯកសារ D308/3, ដីកាដំណោះស្រាយ (សំអាងហេតុ), ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ កថាខណ្ឌ ១៥ (ដកស្រង់ពីសំណុំរឿង ០០២ ឯកសារ D427/2/15 សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំង នឹងដីកាដំណោះស្រាយ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ១០៣)។

[13] សំណុំរឿង ០០២ ឯកសារ D427/2/15 សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ១០៣("ច្បាប់ អ.វ.ត.ក មិនបានផ្តល់អំណាចដល់រាជរដ្ឋាភិបាលកម្ពុជា *ធ្វើការចោទប្រកាន់មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ឬបុគ្គលដែលត្រូវបានចោទប្រកាន់ថាជាជនទទួលខុសត្រូវខ្ពស់បំផុតលើបទល្មើស*អន្តរជាតិ។ ការមិនផ្តល់អំណាចបែបនេះ មិនសំខាន់នោះទេ។ នៅក្នុងការអនុវត្តយុត្តាធិការមូលដ្ឋានរបស់ខ្លួន រាជរដ្ឋាភិបាលកម្ពុជាមិនត្រឹមតែមានសេរីភាពនៅក្នុងការចោទប្រកាន់បទល្មើសបែបនេះ ដែលបានកើតឡើងលើដែនដី ដែលខ្លួនមានយុត្តាធិការប៉ុណ្ណោះទេ ខ្លួនក៏មានកាតព្វកិច្ចចោទប្រកាន់បទល្មើសបែបនេះផងដែរ តាមច្បាប់អន្តរជាតិ។ ទោះបីជាយ៉ាងនេះក្តី ជាជាងការប្រើប្រាស់រចនាសម្ព័ន្ធតុលាការរបស់ខ្លួនដែលមានស្រាប់រួចទៅហើយ រាជរដ្ឋាភិបាលកម្ពុជាបានព្រមព្រៀងជាមួយនឹងអង្គការសហប្រជាជាតិ បង្កើត អ.វ.ត.ក ដែលមានជំនាញអន្តរជាតិ ហើយបានផ្ទេរយុត្តាធិការទៅឲ្យ អ.វ.ត.ក ធ្វើការជំនុំជម្រះ*លើរឿងក្តីទាំងនេះ*")។ (មានការបញ្ជាក់បន្ថែម និងការដកស្រង់ត្រូវបានលុបចេញ)។ អង្គបុរេជំនុំជម្រះបានប្រើប្រាស់ពាក្យ "ផ្ទេរ" ដើម្បីបញ្ជាក់ពីអំណាចយុត្តាធិការដែលនឹងត្រូវផ្តល់ជូនរាជរដ្ឋាភិបាលកម្ពុជា នៅពេលដែល អ.វ.ត.ក មានអត្ថិភាព។

D308/3/1/9

យុត្តាធិការបុគ្គល ឬយុត្តាធិការបទល្មើសរបស់តុលាការកម្ពុជាសាមញ្ញ ទៅលើព្រឹត្តិការណ៍នានាដែលស្ថិតក្នុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក"[14]។ ក្នុងការធ្វើបែបនេះ ដីកាដំណោះស្រាយអះអាងថានឹងរារាំងតុលាការកម្ពុជាដោយគ្មានលក្ខណ្ឌ មិនឲ្យអនុវត្តយុត្តាធិការលើឧក្រិដ្ឋកម្ម *ណាមួយ និងទាំងអស់* ដែលត្រូវបានប្រព្រឹត្តចាប់ពីខែ មេសា ឆ្នាំ ១៩៧៥ ដល់ខែ មករា ឆ្នាំ ១៩៧៩ ដោយមិនខ្វល់ថាតើសំណុំរឿងនោះនឹងស្ថិតនៅក្នុងយុត្តាធិការមានកម្រិតរបស់ អ.វ.ត.ក ខ្លួនឯង ឬអត់នោះឡើយ។ ប្រសិនបើមានការអនុវត្តដូច្នេះមែន សេចក្តីប្រកាសដ៏ទូលំទូលាយបែបនោះ អាចនឹងមានផលប៉ះពាល់អវិជ្ជមានយ៉ាងធ្ងន់ធ្ងរលើផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះជាច្រើនស្រទាប់វណ្ណៈនៃរបបខ្មែរក្រហម។ ដោយការខិតខំហាមឃាត់តុលាការកម្ពុជាធម្មតា មិនឲ្យបំពេញតួនាទីជាវេទិការកដំណោះស្រាយជូនជនរងគ្រោះនាពេលអនាគតនោះ ដីកាដំណោះស្រាយធ្វើឲ្យខូចមរតករបស់ អ.វ.ត.ក យ៉ាងធ្ងន់ធ្ងរ ដោយការរៀបចំឲ្យមានតុលាការមួយ ដែលការលើកលែងទោសស្ទើរតែទាំងស្រុងលើឧក្រិដ្ឋកម្មឃោរឃៅក្នុងសម័យខ្មែរក្រហម ត្រូវបានអនុវត្តក្នុងប្រទេសកម្ពុជាតាមរយៈយន្តការនេះ។

7. អង្គបុរេជំនុំជម្រះ គឺជាវេទិកាតុលាការតែមួយគត់ ដែលតាមរយៈវេទិកានេះ អង្គបុរេជំនុំជម្រះត្រូវតែកែតម្រូវការសន្និដ្ឋានរបស់ដីកាដំណោះស្រាយ លើយុត្តាធិការរបស់តុលាការកម្ពុជាធម្មតាចំពោះឧក្រិដ្ឋកម្មសម័យខ្មែរក្រហម។ តុលាការកម្ពុជាសាមញ្ញគ្មានសិទ្ធិពិនិត្យឡើងវិញលើដីកាដំណោះស្រាយនោះទេ[15]។ ដោយសារថា យុត្តាធិការនៃតុលាការកម្ពុជាសាមញ្ញមិនពាក់ព័ន្ធនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះនានារបស់ អ.វ.ត.ក បញ្ហានេះគឺមិនទំនងជានឹងត្រូវដោះស្រាយដោយតុលាការកម្ពុជាធម្មតាណាមួយនោះឡើយនៅថ្ងៃអនាគត។ ដូច្នេះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំដោយក្តីគោរពដល់អង្គបុរេជំនុំជម្រះឲ្យដោះស្រាយបញ្ហានេះ តាមរយៈសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាដំណោះស្រាយនេះ។

[14] ឯកសារ D308/3, ដីកាដំណោះស្រាយ (សំអាងហេតុ), ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ កថាខណ្ឌ ២៣(ខ)។

[15] សំណុំរឿងលេខ ០០១/១៨ កក្កដា ឆ្នាំ ២០០៧/ អវតក/កសចស (អបជ) ឯកសារ C5/45 សាលដីកាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០០៧ កថាខណ្ឌ ១៨ ("គ្មានតុលាការនៅក្រៅវចនាសម្ព័នរបស់ អ.វ.ត.ក ណាមួយមានសិទ្ធិសើរើលើសេចក្តីសម្រេចរបស់ អ.វ.ត.ក ហើយដូចគ្នានេះដែ អ.វ.ត.ក ក៏មិនមាន សិទ្ធិសើរើលើសេចក្តីសម្រេចរបស់តុលាការណាមួយដែលមិនស្ថិតក្នុងវចនាសម្ព័ន្ធរបស់ខ្លួនដែរ")។

D308/3/1/9

ការខកខានមិនបានធ្វើដូច្នេះ នឹងធ្វើឲ្យសេចក្ដីសន្និដ្ឋានក្នុងដីកាដំណោះស្រាយ ក្លាយជាជំហរពិតប្រាកដរបស់ អ.វ.ត.ក លើបញ្ហានេះ ដែលជាលទ្ធផល វាប៉ះពាល់ដល់ផលប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី និងមរតករបស់តុលាការនេះ។ លើសពីនេះទៀត ដូចដែលបានរៀបរាប់លម្អិតនៅក្នុងផ្នែកទី II *ខាងក្រោម* ការសម្រេចរបស់ដីកាដំណោះស្រាយដែលថា តុលាការកម្ពុជាធម្មតាត្រូវបានហាមឃាត់មិនឲ្យអនុវត្តយុត្តាធិការលើ លើឧក្រិដ្ឋកម្មទាំងអស់ក្នុងសម័យខ្មែរក្រហម គឺជាការបំពានលើច្បាប់អន្តរជាតិ និងច្បាប់កម្ពុជា។

## II. ការបកស្រាយកិច្ចព្រមព្រៀង និងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ថាជាការរារាំងយុត្តាធិការរបស់តុលាការកម្ពុជាសាមញ្ញលើបុគ្គល ឬព្រឹត្តិការណ៍ដែលស្ថិតនៅក្រៅយុត្តាធិការមានកម្រិតរបស់ អ.វ.ត.ក អាចជាការបំពានលើច្បាប់អន្តរជាតិ និងច្បាប់កម្ពុជា

8. ខ្លឹមសារធម្មតានៃកិច្ចព្រមព្រៀងស្ដីពីការបង្កើត អ.វ.ត.ក[16] ដែលត្រូវបានបកស្រាយក្នុងបរិបទនៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក[17] នាំទៅដល់ការសន្និដ្ឋានថា តុលាការកម្ពុជាសាមញ្ញមានយុត្តាធិការលើឧក្រិដ្ឋកម្ម ដែលមិនស្ថិតក្នុងយុត្តាធិការមានកម្រិតរបស់ អ.វ.ត.ក។ ការបកស្រាយផ្ទុយគ្នានេះបំពានលើច្បាប់អន្តរជាតិ និងច្បាប់កម្ពុជា ដែលក្នុងនោះ ការបកស្រាយនេះ (ក) មានលក្ខណៈផ្ទុយគ្នាពីការបកស្រាយលក្ខខណ្ឌធម្មតានៃកម្មវត្ថុ និងគោលបំណងនៃកិច្ចព្រមព្រៀងស្ដីពីការបង្កើត អ.វ.ត.ក (ខ) ប្រទាំងទិសគ្នាជាមួយការងាររៀបចំ និងការប្រព្រឹត្តជាបន្តបន្ទាប់របស់ភាគីនីមួយៗ និង (គ) បំពានលើច្បាប់កម្ពុជា។

### ក. <u>មាត្រា ១ នៃកិច្ចព្រមព្រៀង និងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ត្រូវតែបកស្រាយដោយអនុលោមតាមគោលការណ៍ច្បាប់អន្តរជាតិស្ដីពីការបកស្រាយសន្ធិសញ្ញា</u>

9. ក្រោមគោលការណ៍ជាមូលដ្ឋាននៃការបកស្រាយសន្ធិសញ្ញា ដែលបានចងក្រងនៅក្នុងអនុសញ្ញាទីក្រុងវីយែនស្ដីពីច្បាប់នៃសន្ធិសញ្ញា ដែលជាទូទៅអនុវត្តចំពោះសន្ធិសញ្ញាទាំងអស់ និង

---

[16] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ភ្នំពេញ ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០៣ ("កិច្ចព្រមព្រៀង អ.វ.ត.ក")។

[17] ច្បាប់ស្ដីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០១ បូកជាមួយច្បាប់វិសោធនកម្មដែលបានប្រកាសឲ្យប្រើ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ ("ច្បាប់ អ.វ.ត.ក")។

D308/3/1/9

ជាពិសេស ដាក់បញ្ចូលក្នុងមាត្រា ២(២) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក] សន្ធិសញ្ញាមួយត្រូវតែបកស្រាយដោយផ្អែកលើអត្ថន័យធម្មតារបស់ខ្លួន តាមបរិបទនៃកម្មវត្ថុ និងគោលបំណងរបស់ខ្លួន[18]។ មាត្រា ៣១(១) នៃអនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់នៃសន្ធិសញ្ញា តម្រូវឱ្យមានការបកស្រាយសន្ធិសញ្ញាមួយ "ដោយសុទ្ធចិត្ត អនុលោមតាមអត្ថន័យធម្មតា ដែលត្រូវតាមបរិបទរបស់ខ្លួន និងតាមកម្មវត្ថុ និងគោលបំណងនៃន្ធិសញ្ញានេះ"[19]។ មធ្យោបាយបន្ថែមសម្រាប់ការបកស្រាយនេះ គឺមាននៅក្នុងមាត្រា ៣២ ពាក់ព័ន្ធនឹងការងាររៀបចំនៃសន្ធិសញ្ញា និងបរិបទនៃការបកស្រាយនេះដើម្បីបញ្ជាក់ពីអត្ថន័យដែលការបកស្រាយតាមមាត្រា ៣១ នាំដល់អត្ថន័យ "មិនច្បាស់លាស់ ឬពិបាកយល់" ឬលទ្ធផល "មិនទំនង ឬមិនសមហេតុផលច្បាស់ក្រឡែត"[20]។ ជាចុងក្រោយ ការអនុវត្តរបស់រដ្ឋភាគី រួមបញ្ចូលទាំងកិច្ចព្រមព្រៀងបន្តបន្ទាប់ណាមួយរវាងភាគីទាំងអស់ ឬការអនុវត្តនៅពេលក្រោយៗណាមួយក្នុងការប្រើប្រាស់សន្ធិសញ្ញានេះ គឺជាវិធីសាស្ត្រយថាភាពនៃការបកស្រាយសន្ធិសញ្ញា និងអាចនឹងមានកំណត់ ប្រសិនបើមាន[21]។ ការវិភាគ អនុលោមតាមអនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញា មានដូចខាងក្រោម។

## ១. ការបកស្រាយរបស់ ក.ស.ច.ស មិនអើពើនឹងអត្ថន័យសាមញ្ញ និងបរិបទនៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក ឡើយ ខណៈដែលការបកស្រាយនេះនាំឱ្យអធិបតេយ្យភាពរបស់កម្ពុជាបំពានមាត្រា ៣១ នៃអនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់សន្ធិសញ្ញា

10. ការបកស្រាយរបស់ ក.ស.ច.ស មិនអើពើនឹងអត្ថន័យសាមញ្ញ និងបរិបទនៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក ដែលច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ជាផ្នែកមួយសំខាន់ និងមានភាពផ្ទុយគ្នាទៅនឹងកម្មវត្ថុ និងគោលបំណងនៃការបកស្រាយច្បាប់នេះ។ មាត្រា ១ នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក ចែងអំពី "មូលដ្ឋានច្បាប់ និងគោលការណ៍" សម្រាប់បង្កើតកិច្ច

---

[18] អនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់សន្ធិសញ្ញា (ជាមួយឧបសម្ព័ន្ធ) (ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ១៩៦៩), 1155 U.N.T.S. 331 ("VCLT"), មាត្រា ៣១-៣២។

[19] *ដូចជើងទំព័រខាងលើ*។ មាត្រា ៣១ នៃអនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់សន្ធិសញ្ញា ឆ្លុះបញ្ចាំងពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ *សូមមើល* ឧទាហរណ៍ *Kasikili/Sedudu Island (Botswana/Namibia)*, សាលក្រម (ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ១៩៩៩) របាយការណ៍របស់ ស.ព.អ ឆ្នាំ ១៩៩៩ ទំព័រ ១០៥៩ កថាខណ្ឌ ១៨។

[20] អនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់សន្ធិសញ្ញា, មាត្រា ៣២។

[21] *សូមមើល* ដូចជើងទំព័រខាងលើ មាត្រា ៣១(៣)(ក) និង(ខ)។

D308/3/1/9

សហប្រតិបត្តិការរវាងអង្គការសហប្រជាជាតិ និងប្រទេសកម្ពុជាក្នុង “ការវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់ ... និងជនដែលទទួលខុសត្រូវខ្ពស់បំផុត” ចំពោះការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ ដែលបានប្រព្រឹត្តក្នុងសម័យខ្មែរក្រហម។ មាត្រា ២ ទទួលស្គាល់ថា អ.វ.ត.ក មានយុត្តាធិការបុគ្គលលើមេដឹកនាំជាន់ខ្ពស់ និងជនដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មទាំងនេះ[22]។ ពុំមានការចែងនៅក្នុងកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក អំពីការគ្រប់គ្រងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយមន្ត្រីថ្នាក់ទាបក្នុងរបបខ្មែរក្រហម ឬដោយបុគ្គលដែលស្ថិតនៅក្រៅយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឡើយ។ កិច្ចព្រមព្រៀងនេះក៏ពុំមានការចែងពាក់ព័ន្ធនឹងការលុបយុត្តាធិការរបស់តុលាការកម្ពុជាសាមញ្ញលើឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តដោយបុគ្គលថ្នាក់ទាបក្នុងអំឡុងរបបខ្មែរក្រហមនោះដែរ។ ដូច្នេះ អត្ថន័យធម្មតា គឺគ្មានការហាមឃាត់លើការអនុវត្តយុត្តាធិការពិសេស ដោយតុលាការកម្ពុជាសាមញ្ញលើឧក្រិដ្ឋកម្មដែលស្ថិតនៅក្រៅវិសាលភាពមានកម្រិតរបស់ អ.វ.ត.ក នោះទេ។

11. ជាការពិតណាស់ រដ្ឋមានសិទ្ធិអំណាចពិសេសក្នុងការគ្រប់គ្រង និងចេញយុត្តាធិការជាតិរបស់ខ្លួនអនុលោមតាមមាត្រា ២(៧) នៃធម្មនុញ្ញអង្គការសហប្រជាជាតិ។ ដំណោះស្រាយជាច្រើនដែលអនុម័តដោយមហាសន្និបាត និងអង្គភាពផ្សេងៗរបស់អង្គការសហប្រជាជាតិ បានទទួលស្គាល់ថា ការគោរពលើយុត្តាធិការជាតិ និងអធិបតេយ្យភាពរបស់រដ្ឋមួយ គឺជាគោលការណ៍ជាមូលដ្ឋាននៃច្បាប់អន្តរជាតិ[23]។ លើសពីនេះទៀត ការអនុវត្តរបស់រដ្ឋក៏បង្ហាញពីយុត្តាធិការជាតិផងដែរលើឧក្រិដ្ឋកម្ម ដែលអាចត្រូវបានចាត់ទុកថាជាការរំលោភលើច្បាប់ព្រហ្មទណ្ឌអន្តរជាតិ

[22] *សូមមើលផងដែរ* បុព្វកថាកិច្ចព្រមព្រៀង អ.វ.ត.ក ( ដើម្បីជំនួយការស្តែងចេញនៃគោលបំណង និងគោលដៅ បុព្វកថាបានចែងស្រដៀងគ្នាថា “ [...] ដោយហេតុថា អាជ្ញាធរកម្ពុជាបានស្នើសុំជំនួយពីអង្គការសហប្រជាជាតិដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជា ទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុង ថ្ងៃ ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ទៅ ថ្ងៃ ៦ ខែ មេសា ឆ្នាំ ១៩៧៩")។

[23] សេចក្តីប្រកាសលើគោលការណ៍លនៃច្បាប់អន្តរជាតិទាក់ទងនឹងទំនាក់ទំនងមិត្តភាព និងសហការគ្នារវាងរដ្ឋ ស្របតាមធម្មនុញ្ញសហប្រជាជាតិ U.N.G.A. A/RES/25/2625 (ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៧០); សេចក្តីប្រកាស និងកម្មវិធីសកម្មភាពស្តីពីវប្បធម៌ និងសន្តិភាព, U.N. GAOR, 53rd Sess., អ.ស.ប.ជ ឯកសារ A/RES/53/243 (ឆ្នាំ ១៩៩៩)។

D308/3/1/9

ដែលជាបទដ្ឋានច្បាប់ទំនៀមទម្លាប់អន្តរជាតិ[24]។

12. ដីកាដំណោះស្រាយនាំមកនូវលទ្ធផលមិនត្រឹមត្រូវ ក្រោមមាត្រា ៣១ នៃអនុសញ្ញាទីក្រុងវីយ៉ែន ស្តីពីច្បាប់សន្ធិសញ្ញា ដែលបានផ្លាស់ប្តូរអធិបតេយ្យភាពរបស់ប្រទេសកម្ពុជា ដោយលះបង់សិទ្ធិស្វ័យរបស់ខ្លួនក្នុងការគ្រប់គ្រងសកម្មភាពនៅក្នុងទឹកដីរបស់ខ្លួន និងអំពើដែលប្រព្រឹត្ត ដោយជនជាតិរបស់ខ្លួន ដោយគ្មានការយល់ព្រមច្បាស់លាស់ពីកម្ពុជាឲ្យធ្វើដូច្នេះឡើយ។

**២. ការបកស្រាយរបស់ ក.ស.ច.ស នាំឲ្យមានលទ្ធផលកាន់តែមិនច្បាស់លាស់ថែមទៀត ដោយបង្កើតការលើកលែងទោសជាទូទៅក្នុងការរំលោភលើកម្មវត្ថុ និងគោលបំណងនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក**

13. ការបកស្រាយយ៉ាងវែងអន្លាយរបស់ ក.ស.ច.ស លើយុត្តាធិការផ្តាច់មុខរបស់ អ.វ.ត.ក ផ្តល់នូវនិទ្ទណ្ឌភាពជាពិសេស *ដោយប្រយោល* ដល់ឧក្រិដ្ឋកម្មឃោរឃៅស្ទើរតែទាំងអស់ ដែលបានប្រព្រឹត្តក្នុងសម័យខ្មែរក្រហម ដែលជាលទ្ធផល កាន់តែមិនត្រឹមត្រូវថែមទៀតយោងតាមមាត្រា ៣១ នៃអនុសញ្ញាទីក្រុងវីយ៉ែនស្តីពីច្បាប់សន្ធិសញ្ញា។ មានកិច្ចព្រមព្រៀងយ៉ាងទូលំទូលាយដែលថា ការលើកលែងទោសថ្នាក់ជាតិចំពោះឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរ គឺគ្មានសុពលភាពឡើយនៅក្រោមច្បាប់អន្តរជាតិ[25]។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ខ្លួនឯងបានសង្កេត

---

[24] សូមមើល ឧទាហរណ៍ អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និងការប្រព្រឹត្ត ទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ឬទារ ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៨៤ មាត្រា ៥; មតិទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ លេខ ៣១ (៨០) ឯកសារ អ.ស.ប.ជ CCPRIC/21/Rev.1/Add.13, ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៤ ("មតិទូទៅ លេខ ៣១ ") កថាខណ្ឌ ១៥ ១៨ (លក្ខណៈនៃកាតព្វកិច្ចច្បាប់ដែលដាក់ទៅលើភាគីរដ្ឋ); *Bautista de Arellana តទល់នឹង Colombia,* មតិលេខ 563/1993, ឯកសារ អ.ស.ប.ជ CCPR/C/55/D/563/1993 (1995), Views, គណៈកម្មាធិការសិទ្ធិមនុស្ស ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៩៥ កថាខណ្ឌ ៨៦ ("ភាគីរដ្ឋស្ថិតនៅក្រោមកតព្វកិច្ចក្នុងការស៊ើបអង្កេតការចោទប្រកាន់នៃការប្រឆាំងសិទ្ធិមនុស្ស... និងផ្តន្ទាទោសឧក្រិដ្ឋកម្មនោះ និងអ្នកដែលប្រព្រឹត្តការប្រឆាំង")។

[25] *សូមមើល* ឧទាហរណ៍ ការិយាល័យឧត្តមស្នងការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស ("OHCHR"), លិខិតុបករណ៍នីតិរដ្ឋសម្រាប់រដ្ឋក្រោយមានជម្លោះ៖ ការលើកលែងទោស (២០០៩), ជំពូក ២ ទំព័រ ១១ (ដោយកត់សម្គាល់ឃើញថា “ការលើកលែងទោសមិនត្រូវបានអនុញ្ញាតឡើយ ប្រសិនបើការលើកលែងទោសទាំងនោះ (ក) ការពារមិនឲ្យមានការកាត់ទោសបុគ្គលដែលអាចមានការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មសង្គ្រាម អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬការរំលោភធ្ងន់ធ្ងរលើសិទ្ធិមនុស្ស រួមទាំងការរំលោភបំពានខាងយេនឌ័រជាក់លាក់ផង។ *រដ្ឋរាជអាជ្ញា តទល់នឹង Furundzija* រឿងក្តីលេខ IT-95-17-11-T, សាលក្រម អង្គជំនុំជម្រះ ICTY ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៩៨

D308/3/1/9

ឃើញថា ប្រទេសកម្ពុជាមានកាតព្វកិច្ចក្នុងការកាត់ទោស ឬធ្វើបត្យាប័នជនដែលបានរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ និងអំពើប្រល័យពូជសាសន៍ ដែលមានចែងក្នុងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ឆ្នាំ ១៩៤៨[26]។ ក៏មានការមូលមតិគ្នាកាន់តែច្រើនឡើងៗផងដែរថា ការលើកលែងទោសថ្នាក់ជាតិ លើឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដូចជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិជាដើម គឺគ្មានសុពលភាព អនុលោមតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ[27]។ សម្រាប់បទដ្ឋាន និងកាតព្វកិច្ចអន្តរជាតិទាំងនេះ ដីកាដំណោះស្រាយ ទោះជាយ៉ាងណាសន្មតថា អង្គការសហប្រជាជាតិ និងប្រទេសកម្ពុជាមានឆន្ទៈចុះហត្ថលេខា ហើយហេតុដូច្នេះមានឯកភាពរបស់ខ្លួនជាមួយនឹងកិច្ចព្រមព្រៀងដែលបានចែងយ៉ាងទូលំទូលាយអំពីនិទ្ទណ្ឌភាព *ជាក់ស្តែង* ចំពោះឧក្រិដ្ឋកម្មនៃអំពើឃោរឃៅ។

14. ដូចដែលបានរៀបរាប់លម្អិតនៅក្នុងឧបសម្ព័ន្ធ ក សេចក្តីថ្លែងការណ៍របស់សាស្ត្រាចារ្យ David Scheffer អតីតឯកអគ្គរដ្ឋទូតគោចរអាមេរិកទទួលបន្ទុកបញ្ហាឧក្រិដ្ឋកម្មសង្គ្រាម ដែលមានតួនាទីយ៉ាងសំខាន់នៅក្នុងការបង្កើត អ.វ.ត.ក កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក "គឺជាលទ្ធផលនៃការពិភាក្សាសម្រេចយ៉ាងប្រិតប្រៀនអស់រយៈពេលជាច្រើនឆ្នាំ"[28]។ គេស្ទើរតែមិនជឿថា ចេតនាដែលមិនបង្ហាញត្រង់ៗក្នុងការដកតុលាការកម្ពុជា

---

កថាខណ្ឌ ១៥៥-១៥៦ (ដោយធ្វើការកត់សម្គាល់ក្នុងការវិភាគរបស់ខ្លួនលើការធ្វើទារុណកម្មជាទម្រង់ឧក្រិដ្ឋកម្ម *ដែលមានចែងដោយគោលការណ៍ជាសារវន្ត* ថា "ចារីនៃអំពើទារុណកម្មដែលបានប្រព្រឹត្តទៅលើ ឬបានទទួលផលប្រយោជន៍ពី [វិធានការថ្នាក់ជាតិដែលអនុញ្ញាតឲ្យមាន ឬទទួលយកអំពើទារុណកម្ម ឬឲ្យចារីរួចពីទោស តាមរយៈច្បាប់លើកលែងទោស] ទោះជាយ៉ាងក៏ដោយ អាចទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើទារុណកម្ម បើទោះបីស្ថិតក្នុងរដ្ឋបរទេស ឬរដ្ឋផ្ទាល់ខ្លួនរបស់ចារី ក្នុងរបបបន្ទាប់ទៀតក៏ដោយ")។

[26] សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ ឯកសារ E51/15 សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់ អៀង សារី តាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (*គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ និងការលើកលែងទោស និងការអនុគ្រោះទោស)* ថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០១១ កថាខណ្ឌ ៣៧-៥២។

[27] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស, ជំពូក ២ កថាខណ្ឌ ១១; មតិទូទៅលេខ ៣១ កថាខណ្ឌ ១៨។ *រដ្ឋអាជ្ញា តទល់នឹង Erdemovic,* រឿងក្តីលេខ IT -96-22-T, សាលក្រមនៃការដាក់ទោស អង្គជំនុំជម្រះ ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ កថាខណ្ឌ ២៨។ រឿងក្តី *Almonacid-Arellano* និង*អ្នកផ្សេងទៀត តទល់នឹង Chile,* តុលាការអន្តរអាមេរិកទទួលបន្ទុកសិទ្ធិមនុស្ស សាលក្រម ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០៦ កថាខណ្ឌ ១១៤ (ដោយកំណត់ថា "រដ្ឋមិនអាចបដិសេធកាតព្វកិច្ចក្នុងការស៊ើបអង្កេត កំណត់ និងដាក់ទោសអ្នកដែលទទួលខុសត្រូវព្រហ្មទណ្ឌលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយចាត់វិធានការអនុវត្តច្បាប់អនុគ្រោះទោស ឬវិធានការក្នុងស្រុកដែលប្រហាក់ប្រហែល"។

[28] សេចក្តីថ្លែងការណ៍របស់សាស្ត្រាចារ្យ David Scheffer,ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១៧ កថាខណ្ឌ ៨ (ឧបសម្ព័ន្ធ ក)។

D308/3/1/9

ធម្មតាចេញ អាចត្រូវបានរកឃើញនៅក្នុងឯកសារទាំងនេះ ជាពិសេសដោយសារតែជំហររបស់អង្គការសហប្រជាជាតិលើការលើកលែងទោសជាទូទៅ និងជំហរគាំទ្រជាប្រចាំរបស់រដ្ឋាភិបាលកម្ពុជាលើបញ្ហាដែលទាក់ទងនឹងអធិបតេយ្យភាពរបស់ខ្លួន[29]។ "ភាគីម្ខាងៗក៏មិនដែលធ្លាប់ស្នើឡើងក្នុងអំឡុងពេលនៃកិច្ចចរចាទូលំទូលាយ [របស់អតីតឯកអគ្គរដ្ឋទូតគោចរអាមេរិកទទួលបន្ទុកបញ្ហាឧក្រិដ្ឋកម្មសង្គ្រាមនៅពេលនោះរបស់ Scheffer] ជាមួយពួកគេដែលថា មានការបង្ហាញពីចេតនាដូចនេះឡើយ"[30]។

15. សរុបមក ការបកស្រាយរបស់ ក.ស.ច.ស មិនត្រឹមតែប៉ះពាល់អត្ថន័យធម្មតានៃកិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ប៉ុណ្ណោះទេ តែថែមទាំងមានលក្ខណៈផ្ទុយទៅនឹងកម្មវត្ថុ និងគោលបំណងដែលបានចែងពីការកម្រិតយុត្តាធិការរបស់ អ.វ.ត.ក នៅ ត្រឹមមេដឹកនាំជាន់ខ្ពស់ និងជនដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ។ ការបកស្រាយរបស់ ក.ស.ច.ស គឺជាឧទាហរណ៍ដែលគេស្គាល់ជាទូទៅមួយអំពីការចេញហួសច្បាប់ ដែលអះអាងថានឹងដកហូតសិទ្ធិអធិបតេយ្យភាព ពីកម្ពុជាក្នុងការកាត់ទោសសមាជិកនៃរបបខ្មែរក្រហមចំពោះទង្វើ ដែលបានប្រព្រឹត្តនៅក្នុងទឹកដីរបស់ខ្លួន និងចែងអំពីនិទ្ទណ្ឌភាព*ជាក់ស្តែង*។ ការបកស្រាយបែបនេះចាំបាច់ត្រូវតែបានច្រានចោល ពីព្រោះវាពុំស្របទៅនឹងគោលការណ៍នៃការបកស្រាយសន្ធិសញ្ញា ដែលបានចងក្រងឡើង ក្រោមមាត្រា ៣១ នៃអនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញា។

### ខ. ប្រវត្តិចរចា និងការអនុវត្តបន្តបន្ទាប់របស់ភាគីនីមួយៗ មិនគាំទ្រដល់ការបកស្រាយរបស់ ក.ស.ច.ស ឡើយ

16. ការសន្និដ្ឋានដែលថា អ.វ.ត.ក មានយុត្តាធិការផ្តាច់មុខលើរាល់ឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហមទាំងអស់ មិនត្រូវបានគាំទ្រដោយមធ្យោបាយនៃការបកស្រាយបន្ថែម យោងតាមមាត្រ ៣២ នៃអនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញា ដូចដែលបានរៀបរាប់លម្អិតខាងលើឡើយ។ ការបកស្រាយរបស់ ក.ស.ច.ស ត្រូវបានជំទាស់ដោយប្រវត្តិនៃការចរចារបស់ អ.វ.ត.ក និងការអនុវត្តជាបន្តបន្ទាប់ ក៏ដូចជាគោលការណ៍ច្បាប់អន្តរជាតិ ដែលត្រូវបានទទួលស្គាល់ជាទូទៅផងដែរ។

---

[29] សេចក្តីថ្លែងការណ៍របស់សាស្ត្រាចារ្យ David Scheffer, ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១៧, ៨ (ឧបសម្ព័ន្ធ ក)។

[30] សេចក្តីថ្លែងការណ៍របស់សាស្ត្រាចារ្យ David Scheffer, ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១៧, ៨(ឧបសម្ព័ន្ធ ក)។

D308/3/1/9

**១. យុត្តាធិការផ្តាច់មុខលើឧក្រិដ្ឋកម្មសម័យខ្មែរក្រហមទាំងអស់ គឺផ្ទុយគ្នាទៅនឹងការងាររៀបចំ និងកាលៈទេសៈនៃសេចក្តីសន្និដ្ឋានក្នុងកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក**

17. ការងាររៀបចំបញ្ជាក់ថា អ្នករៀបចំសេចក្តីព្រាងនៃកិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានប្រមើលមើលទុកថានឹងបង្កើតសាលាក្តីដែលមានលក្ខណៈអន្តរជាតិមួយ ដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់ និងជនដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហម។ ផ្ទុយទៅវិញ ការដែលអ្នកធ្វើសេចក្តីព្រាងមិនបានស្រមើលមើលទុកថា អ.វ.ត.ក នឹងកាត់ទោសបុគ្គលគ្រប់រូបដែលរំលោភលើច្បាប់អន្តរជាតិក្នុងអំឡុងពេលដែលពាក់ព័ន្ធ *មិនបាន* នាំដល់ការសន្និដ្ឋានដែលថា ជនទាំងនោះគឺជាបុគ្គល *តែមួយក្រុម*ដែលអាចនឹងត្រូវកាត់ទោសនោះឡើយ។ ដូចបានរៀបរាប់ខាងក្រោម រដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិបានតាក់តែងការឆ្លើយតបមួយ ទៅនឹងឧក្រិដ្ឋកម្មនានាក្នុងរបបខ្មែរក្រហមដើម្បីដោះស្រាយបញ្ហានិទ្ទណ្ឌភាព អនុវត្តឲ្យស្របតាមបទដ្ឋានអន្តរជាតិ និងទាញយកមេរៀនជាបទពិសោធពីតុលាការអន្តរជាតិពិសេសសម្រាប់ប្រទេសរវ៉ាន់ដា និងអតីតប្រទេសយូហ្គោស្លាវី។

18. នៅឆ្នាំ ១៩៩៧ តំណាងពិសេសរបស់អគ្គលេខាធិការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាបានដាក់របាយការណ៍មួយ ដែលបានចងក្រងជាឯកសារនូវ "ក្តីកង្វល់ធ្ងន់ធ្ងរ" របស់គាត់ក៏ដូចជាក្តីកង្វល់របស់គណៈកម្មការសិទ្ធិមនុស្ស ជុំវិញនិទ្ទណ្ឌភាពដែលនៅតែបន្តលើអំពើឃោរឃៅដែលបានប្រព្រឹត្តដោយខ្មែរក្រហម[31]។ គណៈកម្មការសិទ្ធិមនុស្ស "បានអំពាវនាវដល់រដ្ឋាភិបាលកម្ពុជាឲ្យកាត់ទោស ដោយអនុលោមតាមដំណើរការសមស្របនៃច្បាប់ និងបទដ្ឋានអន្តរជាតិដែលទាក់ទងទៅនឹងសិទ្ធិមនុស្ស នូវជនទាំងអស់ដែលបានប្រព្រឹត្តអំពើរំលោភសិទ្ធិមនុស្ស"[32]។ វាច្បាស់ណាស់ថា ការលើកលែងទោសជាទូទៅចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយពួកខ្មែរក្រហម មិនដែលត្រូវបានប្រមើលមើលឃើញឡើយនៅក្នុងរបាយការណ៍របស់

---

[31] ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា តំណាងឲ្យតំណាងពិសេសរបស់អគ្គលេខាធិការសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា លោក Thomas Hammarberg បានបញ្ជូនដោយគោរពនូវដំណោះស្រាយរបស់គណៈកម្មការ លេខ 1996/54 ("របាយការណ៍ Hammarberg ឆ្នាំ ១៩៩៧") កថាខណ្ឌ ៨ ឯកសារ E/CN.4/1997/85 (ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩៧)។

[32] របាយការណ៍ Hammarberg ឆ្នាំ ១៩៩៧ កថាខណ្ឌ ៨; *សូមមើលផងដែរដូចជើងទំព័រខាងលើ* កថាខណ្ឌ ៧១ ("ភាពប្រឈមដែលធ្ងន់ធ្ងរជាងគេក្នុងការផ្សព្វផ្សាយ និងការការពារសិទ្ធមនុស្សនៅកម្ពុជាគឺនិទ្ទណ្ឌភាព")។

D308/3/1/9

តំណាងពិសេសរូបនេះ[33]។

19. នៅក្នុងលិខិតដូចគ្នាចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ១៩៩៧ សហនាយករដ្ឋមន្ត្រី ហ៊ុន សែន និង ព្រះអង្គម្ចាស់ រណឫទ្ធិ បានស្នើសុំជំនួយពីអង្គការសហប្រជាជាតិឲ្យវិនិច្ឆ័យទោសជនដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយរបបខ្មែរក្រហមពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[34]។ សហនាយករដ្ឋមន្ត្រីបាន "ដឹងពីកិច្ចខិតខំប្រឹងប្រែងស្រដៀងគ្នានេះដើម្បីឆ្លើយតបទៅនឹងអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងប្រទេសរវ៉ាន់ដា និងអតីតប្រទេសយូហ្គោស្លាវី និងបានស្នើសុំជំនួយស្រដៀងគ្នាសម្រាប់ប្រទេសកម្ពុជា"[35]។

20. មហាសន្និបាតបានអនុម័តសេចក្តីសម្រេច លេខ ៥២/១៣៥ ដើម្បីដោះស្រាយស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា និងឆ្លើយតបទៅនឹងសំណើសុំជំនួយរបស់រដ្ឋាភិបាលកម្ពុជា។ កង្វល់មួយក្នុងចំណោមកង្វល់នានារបស់មហាសន្និបាតគឺ "បញ្ហានិទ្ទណ្ឌភាពដែលនៅតែមានបន្ត"[36]។ មហាសន្និបាតនេះបាន "អំពាវនាវឲ្យរដ្ឋាភិបាលកម្ពុជាកាត់ទោសដោយអនុលោមតាមដំណើរការសមស្របនៃច្បាប់ និងបទដ្ឋានអន្តរជាតិដែលទាក់ទងទៅនឹងសិទ្ធិមនុស្សនូវជនទាំងអស់ដែលបានប្រព្រឹត្តអំពើរំលោភសិទ្ធិមនុស្ស"[37]។ មហាសន្និបាតបាន "ជំរុញបន្ថែមទៀតដល់រដ្ឋាភិបាលកម្ពុជា

---

[33] របាយការណ៍ Hammarberg ឆ្នាំ ១៩៩៧ កថាខណ្ឌ ៧៤ ("ការពិភាក្សាលម្អិតពីបញ្ហានៃនិទ្ទណ្ឌភាពគឺការចាំបាច់ នៅក្នុងប្រទេសកម្ពុជា ប្រឆាំងនឹងប្រវត្តិនៃការប្រឆាំងនឹងសិទ្ធិមនុស្សជារួមដែលបានប្រព្រឹត្តទៅនៅទសវត្សឆ្នាំ ១៩៧០។ ក្នុងរយៈពេលខ្លី វាអាចពុំមានភាពសមស្របខាងនយោបាយ ក្នុងការជំរុញឲ្យមានការស៊ើបអង្កេតល្អិតល្អន់លើអ្វីដែលកើតមាន និងអ្នកដែលទទួលខុសត្រូវ ប៉ុន្តែតំណាងពិសេសជឿជាក់ថា ការខិតខំប្រឹងប្រែងទាំងនេះ មានភាពចាំបាច់ក្នុងការបង្ហាញថា ឧក្រិដ្ឋកម្មដែលមានលក្ខណៈសាហាវឃោរឃៅនេះមិនអាចទទួលយកបានឡើយ។ វានឹងប៉ះពាល់ទៅដល់ភាពយុត្តិធម៌នៅក្នុងសង្គម បើការសម្លាប់របស់ខ្មែរក្រហម និងអំពើឃោរឃៅដទៃទៀតត្រូវបានអនុគ្រោះក្នុងរបៀបដែលអាចទប់ស្កាត់ និងរារាំងដល់ដំណើរការតុលាការ")។

[34] លិខិតដូចគ្នា ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៧ ពីអគ្គលេខាធិការអង្គការសហប្រជាជាតិ ទៅប្រធានមហាសន្និបាតអង្គការសហប្រជាជាតិ និងប្រធាននៃក្រុមប្រឹក្សាសន្តិសុខ អ.ស.ប.ជ ឯកសារ A/51/930 (ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៧)។

[35] សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ លេខ 52/135, កថាខណ្ឌ ៩ ឯកសារ U.N. Doc. A/RES/52/135 (ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៨)។

[36] សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ លេខ 52/135, កថាខណ្ឌ ៥ ឯកសារ U.N. Doc. A/RES/52/135 (ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៨)។

[37] សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ លេខ 52/135, កថាខណ្ឌ ៦ ឯកសារ U.N. Doc. A/RES/52/135 (ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៨)។

D308/3/1/9

ដោយចាត់ទុកជាការងារជាអាទិភាពខ្ពស់ក្នុងការស៊ើបអង្កេតឲ្យបានហ្មត់ចត់ និងដោយឥតលម្អៀង និងវិនិច្ឆ័យទោសជនដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរបែបនោះ”[38] ។

21. អ្នកជំនាញមួយក្រុមត្រូវបានកោះប្រជុំ ដោយអនុលោមតាមសេចក្ដីសម្រេច លេខ ៥២/១៣៥ របស់មហាសន្និបាត។ នៅក្នុងអារម្ភកថានៃរបាយការណ៍របស់ក្រុមអ្នកជំនាញសម្រាប់ប្រទេសកម្ពុជានេះ អគ្គលេខាធិការអង្គការសហប្រជាជាតិនៅពេលនោះ គឺលោក កូហ្វីអាណាន់ បានសង្កេតឃើញថា “និទ្ទណ្ឌភាពគឺមិនអាចទទួលយកបានឡើយ ចំពោះអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិផ្សេងទៀត”[39]។ លោកបានបញ្ចុះបញ្ចូលឲ្យមានការគាំទ្រជាខ្លាំងដល់តុលាការដែលមានលក្ខណៈជាអន្តរជាតិ ដោយសម្ដែងនូវមន្ទិលសង្ស័យលើសមត្ថភាពរបស់តុលាការជាតិនៅក្នុងរដ្ឋរបស់ពួកគេពេលនោះ ក្នុងការអនុវត្តការជំនុំជម្រះដែលស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ[40]។ ទោះបីជាប្រទេសកម្ពុជានៅទីបំផុត បានច្រានចោលអនុសាសន៍ដែលឲ្យអង្គការសហប្រជាជាតិបង្កើតតុលាការអន្តរជាតិពិសេសមួយ ដើម្បីកាត់ទោសមន្ត្រីខ្មែរក្រហម ជំនួសឲ្យតុលាការជាតិដែលមានលក្ខណៈអន្តរជាតិក្ដី ក៏របាយការណ៍របស់អ្នកជំនាញក្រុមនេះបង្កើតបានជាឯកសារប្រវត្តិនីតិប្បញ្ញត្តិមួយដ៏សំខាន់នៃកិច្ចព្រមព្រៀង និងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ដែរ។

22. ក្រុមអ្នកជំនាញបានពិនិត្យជម្រើសនានាសម្រាប់វិនិច្ឆ័យទោសបុគ្គលទាំងនោះ។ តាមរយៈបទសម្ភាសរបស់ពួកគេ ក្រុមអ្នកជំនាញបានសង្កេតឃើញថា “សង្គមកម្ពុជានឹងអាចយល់ និងរំកិលខ្លួនចេញពីអតីតកាលរបស់ខ្លួនបាន តែនៅពេលណាដែលខ្លួនមើលឃើញអ្នកដែលបានប្រព្រឹត្តអំពើឃោរឃៅដ៏រង្គាលនេះត្រូវបានវិនិច្ឆ័យទោស ដោយឥតលម្អៀងប៉ុណ្ណោះ”[41]។ ក្រុមអ្នកជំនាញនេះបានផ្ដល់អនុសាសន៍ ក្នុងចំណោមអនុសាសន៍ផ្សេងៗទៀតថា តុលាការអន្តរជាតិដែលបានស្នើឡើង ពុំគួរប៉ុនប៉ង “វិនិច្ឆ័យទោសមនុស្សទាំងអស់ ឬសឹងតែភាគច្រើន ដែលបានប្រព្រឹត្តបំពានច្បាប់អន្តរជាតិ ឬច្បាប់កម្ពុជាក្នុងអំឡុងពេលពាក់ព័ន្ធនោះទេ”[42]។ ការដែលក្រុម

---

[38] លិខិតដូចគ្នា ចុះ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៩ ពីអគ្គលេខាធិការអង្គការសហប្រជាជាតិ ទៅប្រធានមហាសន្និបាតអង្គការសហប្រជាជាតិ និងប្រធាននៃក្រុមប្រឹក្សាសន្តិសុខ ទំព័រ ៣ អ.ស.ប.ជ ឯកសារ A/53/850 (ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ១៩៩៩)។

[39] *ចដើងទំព័រខាងលើ*។

[40] *ដូចដើងទំព័រខាងលើ* កថាខណ្ឌ ១០០។

[41] *ដូចដើងទំព័រខាងលើ* កថាខណ្ឌ ១០៦។

[42] *ដូចដើងទំព័រខាងលើ* កថាខណ្ឌ ១០៦។

D308/3/1/9

អ្នកជំនាញបានប្រមើលដាក់កម្រិតយុត្តាធិការនៅតុលាការអន្តរជាតិ ដែលត្រូវបានស្នើឡើងនោះ ត្រឹមមន្ត្រីជាន់ខ្ពស់ និងជនដែលទទួលខុសត្រូវខ្ពស់បំផុត មិនបាននាំដល់ការសន្និដ្ឋានថា ខ្លួនមានបំណងលើកលែងទោសជាទូទៅចំពោះជនទាំងឡាយណា ដែលស្ថិតនៅក្រៅយុត្តាធិការរបស់ អ.វ.ត.ក នោះទេ។ ដំណោះស្រាយដែលបានស្នើឡើង គឺស្ថិតនៅក្នុងបរិបទនៃការយល់ដឹងទូលំទូលាយពីសមត្ថភាពមានកម្រិតរបស់តុលាការកម្ពុជាក្នុងការស៊ើបអង្កេត និងកាត់សេចក្តីលើសំណុំរឿងទាំងនោះ ក៏ដូចជាការទទួលស្គាល់ថា ការផ្តល់មូលនិធិសម្រាប់តុលាការអន្តរជាតិនេះមានកម្រិតផងដែរ។ ប្រសិនបើតុលាការកម្ពុជាបង្កើនសមត្ថភាពរបស់ខ្លួនក្នុងការកាត់ទោសជនដែលទទួលខុសត្រូវចំពោះការរំលោភបំពានច្បាប់អន្តរជាតិ ក្រោមរបបខ្មែរក្រហម របាយការណ៍នេះគ្មានផ្លូវរារាំងតុលាការទាំងនេះមិនឲ្យធ្វើដូច្នេះនោះទេ។ ដូច្នេះ ទោះជាអ្នកជំនាញបានសន្និដ្ឋានថា គេពុំគួរប៉ុនប៉ងវិនិច្ឆ័យទោសបុគ្គលទាំងអស់នៅតុលាការអន្តរជាតិដែលបានស្នើឡើងក្តី[43] ក៏ប្រវត្តិនីតិប្បញ្ញត្តិមិនបានលើកឡើងថា ជនណាដែលស្ថិតនៅក្រៅយុត្តាធិការរបស់ អ.វ.ត.ក *នឹងមិនអាច*ត្រូវបានវិនិច្ឆ័យទោស នៅក្នុងតុលាការកម្ពុជាសាមញ្ញនោះទេ ប្រសិនបើ និងនៅពេលណាដែលតុលាការធម្មតាទាំងនោះអភិវឌ្ឍសមត្ថភាពខ្លួនឯង ក្នុងការបើកសវនការចំពោះសំណុំរឿងបែបនោះបាន។

23. របាយការណ៍បន្ថែមដោយតំណាងពិសេស ក៏ដូចជាសេចក្តីសម្រេចរបស់មហាសន្និបាត ជួយពង្រឹងសញ្ញាណដែលថា អ.ស.ប និងរដ្ឋជាសមាជិករបស់ អ.ស.ប មិនធ្លាប់បានប្រមើលមើលពីការលើកលែងទោសជាទូទៅ ចំពោះជនល្មើសដែលបានរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរនោះឡើយ ហើយថា កម្ពុជាមានគោលបំណងរក្សាសិទ្ធិអធិបតេយ្យភាពរបស់ខ្លួន ទាក់ទងនឹងរដ្ឋបាល

---

[43] *សូមមើល* ឧទាហរណ៍ ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា របាយការណ៍នៃតំណាង ពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា លោក Thomas Hammarberg បានបញ្ជូនដោយគោរពតាមនូវដំណោះស្រាយរបស់គណៈកម្មការ លេខ 1998/76 ទំព័រ ៣ E/CN.4/2000/109 (ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០០) (ដោយបានរាការណ៍ថា "លោកនាយករដ្ឋមន្ត្រីបានលើឡើងម្តងហើយម្តងទៀតពីក្តីបារម្ភថា ការរៀបចំនៃតុលាការត្រូវគោរពតាមអធិបតេយ្យភាពនៃប្រទេសកម្ពុជា")។ សេចក្តីសម្រេចអង្គការសហប្រជាជាតិ លេខ 54/171, អ.ស.ប.ជ ឯកសារ A/RES/54/171 (ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០០) (ដំណោះស្រាយរបស់មហាសន្និបាទបានសង្កត់ពី "គណនេយ្យភាពនៃចារីម្នាក់ៗ ចំពោះការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ គឺជាសមាសធាតុដ៏សំខាន់នៃការផ្តល់សំណងដែលមានប្រសិទ្ធិភាពដល់ជនរងគ្រោះពីការរំលោភសិទ្ធិមនុស្ស និងជាកត្តាចាំបាច់ក្នុងការធានាឲ្យមានប្រព័ន្ធយុត្តិធម៌ដែលយុត្តិធម៌ និងសមធម៌ និងចុងក្រោយមានការផ្សះផ្សា និងស្ថេរភាពក្នុងរដ្ឋ")។

D308/3/1/9

តុលាការ[44]។ បន្ថែមពីលើនេះទៀត ដូចដែលបានរៀបរាប់លម្អិតនៅក្នុងឧបសម្ព័ន្ធ ក សាស្ត្រាចារ្យ David Scheffer បានបញ្ជាក់ថា ការដកស្រង់សម្រាប់ការស្រាវជ្រាវរបស់លោក នៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ) គឺមិនសមហេតុផល និង "មិនគាំទ្រសំអាងហេតុ របស់សហចៅក្រមស៊ើបអង្កេតនៅលើភាពផ្តាច់មុខនៃយុត្តាធិការរបស់ អ.វ.ត.ក នោះទេ"[45]។ ផ្ទុយទៅវិញ "ប្រវត្តិចរចារបស់ អ.វ.ត.ក ទាញការសន្និដ្ឋានភ្លាមថា ការបង្កើត អ.វ.ត.ក គឺក្នុង គោលបំណងដកយុត្តាធិការដែលនៅសេសសល់ *ទាំងអស់*លើឧក្រិដ្ឋកម្មសម័យខ្មែរក្រហម ពី តុលាការកម្ពុជាសាមញ្ញ"[46]។

24. ទោះជាមានការចង្អុលបង្ហាញពីខាងដើមដែលផ្ទុយពីនេះក្តី ដីកាដំណោះស្រាយ នៅតែបកស្រាយ ថា កង្វះគោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* នៅក្នុងកិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ថាជាការចង្អុលបង្ហាញពីចេតនាជាក់ស្តែងដោយភាគីដែល ចង់ដកយុត្តាធិការរបស់តុលាការកម្ពុជាសាមញ្ញ លើឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហមទាំងអស់[47]។ ដីកាដំណោះស្រាយនេះបកស្រាយខុសអំពីកង្វះមាត្រាបែបនោះ នៅក្នុងឯកសារគោលរបស់ អ.វ. ត.ក។ នៅពេលមានការចរចាបង្កើត អ.វ.ត.ក ប្រព័ន្ធច្បាប់កម្ពុជាខ្វះធនធាន និងសមត្ថភាពក្នុង ការទទួលរ៉ាប់រងជំនុំជម្រះ អំពើឃោរឃៅក្នុងសម័យខ្មែរក្រហមឲ្យបានត្រឹមត្រូវ។ តាមពិត ដោយសារតែកម្ពុជាមិនអាចធ្វើការជំនុំជម្រះក្តីទាំងនេះជាលក្ខណៈជាតិបាន ទើបកម្ពុជាដំបូង ឡើយស្នើសុំជំនួយពីអង្គការសហប្រជាជាតិ[48]។ កង្វះបទប្បញ្ញត្តិកំណត់លើទំនាក់ទំនងរវាង អ.វ.ត.ក និងតុលាការកម្ពុជាសាមញ្ញ ឆ្លុះបញ្ចាំងពីការពិតនៅពេលនោះ មានជាអាទិ៍ដូចជា

[44] សេចក្តីថ្លែងការណ៍របស់សាស្ត្រាចារ្យ David Scheffer, ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១៧ កថាខណ្ឌ ៨ (ឧបសម្ព័ន្ធ ក) (មាន ការបញ្ជាក់បន្ថែមក្នុងច្បាប់ដើម)។

[45] ឯកសារ D308/3, ដីកាដំណោះស្រាយ (សំអាងហេតុ), ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ កថាខណ្ឌ ១៧។

[46] សេចក្តីថ្លែងការណ៍របស់សាស្ត្រាចារ្យ David Scheffer, ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១៧, ៨ (ឧបសម្ព័ន្ធ ក) (មានការបញ្ជាក់ បន្ថែមក្នុងច្បាប់ដើម)។

[47] ឯកសារ D308/3, ដីកាដំណោះស្រាយ (សំអាងហេតុ), ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ កថាខណ្ឌ ១៧។

[48] លិខិតដូចគ្នាចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៧ ពីអគ្គលេខាធិការអង្គការសហប្រជាជាតិ ទៅប្រធានមហាសន្និបាតអង្គការ សហប្រជាជាតិ និងប្រធាននៃក្រុមប្រឹក្សាសន្តិសុខ អ.ស.ប.ជ ឯកសារ A/51/930 (ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៧) ("ប្រទេសកម្ពុជាពុំមានធនធាន ឬជំនាញក្នុងការអនុវត្តនីតិវិធីសំខាន់នេះ។ ដូច្នេះ យើងគិតថាវាជាការចាំបាច់ក្នុងការសុំជំនួយពី អង្គការសហប្រជាជាតិ")។ *សូមមើលផងដែរ* សេចក្តីថ្លែងការណ៍របស់សាស្ត្រាចារ្យ David Scheffer, ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១៧ កថាខណ្ឌ ៨-៩ (ឧបសម្ព័ន្ធ ក)។

D308/3/1/9

តុលាការកម្ពុជាពុំមិនសមត្ថភាពគ្រប់គ្រាន់ ដើម្បីបំពេញដំណើរការជំនុំជម្រះទាំងនេះបានទេ។ ដូច្នេះ មិនចាំបាច់មានការបញ្ជាក់ពីទំនួលខុសត្រូវរឿង១ខ្លួនរបស់តុលាការទាំងនេះទាក់ទងនឹងសំណុំរឿងសម័យខ្មែរក្រហមនោះទេ ជាពិសេសដោយសារតែរយៈពេលខ្លីដែល អ.វ.ត.ក នឹងត្រូវបញ្ចប់អាណត្តិរបស់ខ្លួន[49]។ ចំពោះហេតុផលដូចគ្នានេះ ការសំអាងក្នុងដីកាដំណោះស្រាយលើយុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូល ក្នុងការគាំទ្រការបកស្រាយទូលំទូលាយរបស់ខ្លួនពីភាពផ្តាច់មុខនៃយុត្តាធិការរបស់ អ.វ.ត.ក គឺជាការខុសឆ្គង[50]។ ជាធម្មតា អង្គជំនុំជម្រះតុលាការកំពូលបានទទួលស្គាល់ពីកង្វះយន្តការបញ្ជូនបន្តនៅចំពោះមុខ អ.វ.ត.ក និងដូចគ្នានឹងអង្គបុរេជំនុំជម្រះដែរ បានកត់សម្គាល់ថា អ.វ.ត.ក ត្រូវបានផ្ទេរឲ្យនូវកម្រិតនៃភាពផ្តាច់មុខលើយុត្តាធិការ បើទោះជាវាមិនបានកំណត់ពីវិសាលភាពរបស់ខ្លួនពេញលេញក៏ដោយ[51]។

25. របាយការណ៍របស់អ្នកជំនាញ ការចរចាលើកិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ត្រូវបានបង្កើតឡើង ដោយធ្វើការប្រៀបធៀបទៅនឹងវឌ្ឍនភាពការងាររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់ប្រទេសរវ៉ាន់ដា។ វាជាការរៀបចំឡើងរបស់ប្រទេសកម្ពុជា ក៏ដូចជាអង្គការសហប្រជាជាតិដែរ ដើម្បីដកស្រង់បទពិសោធពីតុលាការផ្សេង១ទៀត។ ទាំងអង្គការសហប្រជាជាតិ ទាំងប្រទេសកម្ពុជា បានធ្វើការយោងជាពិសេសទៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា។ បទប្បញ្ញត្តិយុត្តាធិការនៃលក្ខន្តិកៈរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដានេះ មានភាពទូលំទូលាយច្រើនជាងបទប្បញ្ញត្តិយុត្តាធិការដែលកំពុងអនុវត្តនៅ អ.វ.ត.ក រួមទាំងភាពគ្មានអាជ្ញាយុកាលកំណត់ចំពោះមេដឹកនាំជាន់ខ្ពស់ និងជនដែលទទួលខុសត្រូវខ្ពស់បំផុតផង[52]។ ទោះជាយ៉ាងណាក៏ដោយ ក្នុងអំឡុង

---

[49] របាយការណ៍របស់អគ្គលេខាធិការនៃអង្គការសហប្រជាជាតិលើសវនការខ្មែរក្រហម អ.ស.ប.ជ ឯកសារ A/57/769 កថាខណ្ឌ ៥៦ (ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣)។

[50] ឯកសារ D308/3, ដីកាដំណោះស្រាយ (សំអាងហេតុ), ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ កថាខណ្ឌ ១២-១៤។

[51] សំណុំរឿង ០០១ ឯកសា F28 *សាលដីកាសម្រេចលើបណ្តឹង ០០១* ថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ៧១។

[52] អនុលោមតាមមាត្រា ៦ នៃលក្ខន្តិកៈតុលាការ ICTY សវនការមានយុត្តាធិការទៅលើ "សំអាងហេតុធម្មតាទាំងអស់" ។ លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី មាត្រា ៦ ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៩៣, ៣២

D308/3/1/9

ទសវត្សរ៍ឆ្នាំ ១៩៩០ និងដើមទសវត្សរ៍ឆ្នាំ ២០០០ វាមានភាពកាន់តែច្បាស់ដែលថា តុលាការមិនអចិន្ត្រៃយ៍មិនមានសមត្ថភាពដោះស្រាយសំណុំរឿង ដែលតម្រូវឱ្យវិនិច្ឆ័យទោសរាល់ជនទាំងអស់ដែលស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ខ្លួន។ ដូច្នេះ តុលាការទាំងនេះបានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចប់ដើម្បីអាចឱ្យពួកគេបញ្ចប់ការងាររបស់ខ្លួនបាន[53]។ យុទ្ធសាស្ត្រទាំងនេះត្រូវបានបង្កើតឡើង សម្រាប់ផ្ទេរសំណុំរឿងមន្ត្រីថ្នាក់កណ្ដាល និងមន្ត្រីថ្នាក់ទាបទៅឱ្យយុត្តាធិការជាតិមានសមត្ថកិច្ច ដែលបានបង្កើនសមត្ថភាពរបស់ខ្លួនរួច។ យុទ្ធសាស្ត្របញ្ចប់របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា ជំរុញឱ្យតុលាការទាំងអស់ផ្ដោតលើ "ការកាត់ទោស និងការជំនុំជម្រះក្ដីមេដឹកនាំជាន់ខ្ពស់បំផុត ដែលគេសង្ស័យថាទទួលខុសត្រូវខ្ពស់បំផុត" លើឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តនោះ[54]។ អនុសាសន៍របស់ក្រុមអ្នកជំនាញដែលឱ្យតុលាការនីមួយៗ "ផ្ដោតលើជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរបំផុតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ" ត្រូវបានព្រាងឡើងនៅចំពេលដែលអនុសាសន៍នេះត្រូវគេយល់ថា តុលាការមិនអចិន្ត្រៃយ៍ដែលមានស្រាប់ កំពុងតែជួបការលំបាកជាមួយនឹងសំណុំរឿងរបស់ខ្លួន។ ដូច្នេះ ការងាកទៅរកវិសាលភាពកាន់តែមានកម្រិតនៃសំណុំរឿងសម្រាប់ អ.វ.ត.ក ពោលគឺការងាកទៅផ្ដោតលើមេដឹកនាំជាន់ខ្ពស់ និងជនដែលទទួលខុសត្រូវខ្ពស់បំផុត ជាជាងទៅលើទស្សនៈទូលំទូលាយនៃយុត្តាធិការបុគ្គល ដែលគេមើលឃើញដំបូងក្នុងលក្ខន្តិកៈរបស់តុលាការមិនអចិន្ត្រៃយ៍ គឺជាផលិតផលនៃមេរៀនដែលគេរៀនសូត្របាន មិនមែនជាលទ្ធផលនៃចេតនាដែលចង់ផ្ដល់និទ្ទណ្ឌភាព ទៅឱ្យចារីសម័យខ្មែរក្រហមទាំងអស់ផ្សេងទៀតនោះទេ។

**២. សេចក្ដីថ្លែងការណ៍ និងការអនុវត្តបន្តបន្ទាប់ ក្រោយពេលបង្កើត អ.វ.ត.ក ខកខានក៏មិនបានគាំទ្រការបកស្រាយរបស់ ក.ស.ច.ស នោះដែរ**

26. ដីកាដំណោះស្រាយនេះ ខកខានមិនបានបញ្ជាក់ពីសេចក្ដីថ្លែងការណ៍ណាមួយ ដែលធ្វើឡើងដោយ

---

I.L.M. 1192។ ដូចគ្នានេះដែរ នៅក្រោមលក្ខន្តិកៈនៃ ICTR សវនការមាន "យុត្តាធិការទៅលើជនគ្រប់រូប"។ លក្ខន្តិកៈនៃតុលាការអន្តរជាតិសម្រាប់រវ៉ាន់ដា មាត្រា ៥ ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤, ៣៣ I.L.M. 1602។

[53] សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល លេខ 1503, U.N. ឯកសារ S/RES/1503 (ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៣)។

[54] *ដូចជើងទំព័រខាងលើ។*

D308/3/1/9

អង្គការសហប្រជាជាតិ ឬរដ្ឋាភិបាលកម្ពុជាបន្ទាប់ពីការបង្កើត អ.វ.ត.ក ដែលនឹងគាំទ្រការបកស្រាយរបស់ខ្លួនឡើយ។ ប្រសិនបើមានដូចនេះមែន សេចក្តីថ្លែងការណ៍សាធារណៈដែលមានគឺប្រឆាំងទៅនឹងការបកស្រាយរបស់ ក.ស.ច.ស ព្រោះទាំងរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិបានបន្តលើកឡើងពីការប្រយុទ្ធប្រឆាំងនឹងនិទ្ទណ្ឌភាព ដែលជារឿងសំខាន់សម្រាប់ដោះស្រាយមរតករបស់ខ្មែរក្រហម[55]។

27. វាជារឿងគួរឲ្យកត់សម្គាល់ អង្គភាពជាច្រើនរបស់ អ.វ.ត.ក បានប្រកាន់យកជំហរដែលថា ការកាត់ទោសឧក្រិដ្ឋកម្មសម័យខ្មែរក្រហមនៅចំពោះមុខតុលាការកម្ពុជាសាមញ្ញ *គឺអាច*ធ្វើទៅបាន។ សហព្រះរាជអាជ្ញា និងក្រុមមេធាវីការពារចុងចោទរបស់ អ.វ.ត.ក ជាច្រើនក្រុមខុសៗគ្នា បានសង្ខេបម្តងហើយម្តងទៀតនូវបញ្ហាសិទ្ធិប្រឆាំងនឹងការធ្វើពិរុទ្ធកម្មខ្លួនឯង និងកម្រិតដែល អ.វ.ត.ក អាចផ្តល់ការធានាអះអាងអំពីការមិនធ្វើការកាត់ទោស នៅចំពោះមុខ អ.វ.ត.ក ឬនៅក្នុងតុលាការកម្ពុជាណាមួយផ្សេងទៀត នៅក្រោមច្បាប់កម្ពុជាបច្ចុប្បន្ន។ ក្នុងបរិបទនេះ មេធាវីការពារចុងចោទរបស់ អ.វ.ត.ក បានគូសបញ្ជាក់ម្តងហើយម្តងទៀតពីលទ្ធភាពនៃការកាត់ទោសនៅចំពោះមុខតុលាការកម្ពុជាសាមញ្ញ[56]។ ដូចគ្នានេះដែរ ការិយាល័យសហព្រះរាជអាជ្ញា

---

[55] *សូមមើល* ឧទាហរណ៍ សេចក្តីថ្លែងការណ៍រួម ដោយឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន និងអ្នកស្រី Patricia O'Brien, អគ្គលេខាធិការរងទទួលបន្ទុកកិច្ចការច្បាប់ទូទៅ ប្រឹក្សាផ្នែកច្បាប់ UNAKRT (ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១០) (ដោយលើកឡើងថា "ទាំងរដ្ឋាភិបាល និងអង្គការសហប្រជាជាតិមានការប្តេជ្ញាក្នុងការបញ្ចប់និទ្ទណ្ឌភាព ចំពោះអំពើឃោរឃៅក្នុងរបបខ្មែរក្រហម និងគាំទ្រ និងគោរពទាំងស្រុងទៅ អ.វ.ត.ក និងដំណើរការនីតិវិធីឯករាជ្យ។

[56] *សូមមើល* ឧទាហរណ៍សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/ អវតក/អជសដ ឯកសារ E200/1/1, ចម្លើយតបរបស់ អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាដែលសុំការអនុញ្ញាតក្នុងការផ្តល់លិខិតធានាអះអាងអំពីការមិនចោទប្រកាន់ដល់សាក្សីនានា ("... សហព្រះរាជអាជ្ញា បានអះអាងថា លិខិតធានាអះអាងអំពីការមិនចោទប្រកាន់ជូនដំណឹងទៅសាក្សីថា ពាក់ព័ន្ធនឹងព្រឹត្តិការណ៍នានាដែលបានកើតឡើងចន្លោះឆ្នាំ ១៩៧៥ -៧៩ ពួកគេមិនត្រូវបានកាត់ទោសនៅ អ.វ.ត.ក ឬនៅតុលាការកម្ពុជាដទៃទៀតតាមច្បាប់បច្ចុប្បន្នទេ។ អំណះអំណាងនេះធ្វើឲ្យយល់ខុស ដោយសារលិខិតធានាអះអាងអំពីការមិនចោទប្រកាន់ មិនអាចត្រូវបានបង្កើតឡើងដោយយកកម្រិតស្មោះត្រង់ណាមួយ និងស្ថាប័នតុលាការណាមួយទេ ប្រសិនបើវាមានគោលបំណងធានាដល់សាក្សីថា "[មិន] មានលទ្ធភាពចោទប្រកាន់ដល់រូបគាត់" ទោះបីជា លទ្ធភាពនោះមិនទំនងជាអាចមានយ៉ាងណាក៏ដោយ")។ *សូមមើលផងដែរ* ប្រតិចារឹក អង្គជំនុំជម្រះ សំណុំរឿង ០០២ ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១២ ឯកសារ El/63.1 ទំព័រ ១៧ បន្ទាត់ ២១-២៥ ("តាមការពិតនោះថា ... ត្រូវតែធានាថានឹងមានការចោទប្រកាន់ មិនមែនពាក់ព័ន្ធទៅនឹងលទ្ធភាពរបស់គាត់ សមត្ថភាពរបស់គាត់នោះទេ។ គឺថាចម្លើយរបស់គាត់អាចនឹងត្រូវបានចោទប្រកាន់ដោយតុលាការជាតិ... ")។

D308/3/1/9

បានទទួលស្គាល់លទ្ធភាពនេះ បើទោះបីជាវានៅឆ្ងាយពីការកាត់ទោសទាំងនេះក៏ដោយ[57]។ លើសពីនេះទៀត អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ដោយផ្អែកលើលទ្ធភាពនៃការកាត់ទោសបែបនេះក្នុងពេលអនាគត បានអនុញ្ញាតឲ្យសាក្សី មិនបាច់ឆ្លើយនឹងសំណួរដែលខ្លួនខ្លាចថាជាការធ្វើពិរុទ្ធកម្មខ្លួនឯង[58]។ ជាការពិត អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងយ៉ាងច្បាស់លាស់ថា ខ្លួន "ចាត់ទុកការផ្តល់នូវការធានាអះអាងពីការមិនធ្វើការកាត់ទោសនៅចំពោះមុខតុលាការកម្ពុជាផ្សេងទៀត ដោយសារតួនាទី និងក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក ថាជារឿងមិនសមស្របឡើយ"[59]។

28. រហូតមកដល់ពេលនេះ ការពិតជាក់ស្តែងដែលថា គ្មានការស៊ើបអង្កេត ឬការកាត់ទោសលើឧក្រិដ្ឋកម្មសម័យខ្មែរក្រហមនៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ដូចដែល ក.ស.ច.ស បានគូសបញ្ជាក់[60] មិនមែនមានន័យថា ការស៊ើបអង្កេត ឬការកាត់ទោសទាំងនេះមិនអាចធ្វើទៅរួចជា លក្ខណៈ*ផ្លូវច្បាប់* នោះទេ។

## គ. <u>ការបកស្រាយរបស់ ក.ស.ច.ស គឺផ្ទុយទៅនឹងច្បាប់កម្ពុជា</u>

29. ដីកាដំណោះស្រាយគឺផ្ទុយទៅនឹងច្បាប់កម្ពុជា ដែលក្នុងនោះវាអះអាងពីការដកហូតមុខងារស្នូលដែលសន្មតដោយរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជាពីតុលាការកម្ពុជាសាមញ្ញ។

---

[57] ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១២ អង្គជំនុំជម្រះ សំណុំរឿង ០០២ ឯកសារ E1/58.1 ទំព័រ ៥៩ បន្ទាត់ ៥-១១ ("លោកប្រធាន! ទាក់ទងទៅនឹង ស-២១ ខ្ញុំមានន័យថា សាក្សីរូបនេះបានផ្តល់ព័ត៌មានច្រើនណាស់ទាក់ទងទៅនឹងការចូលរួមក្នុងសកម្មភាពឧក្រិដ្ឋកម្ម... ដូច្នេះហើយពេលខ្លះទៅ វាសមស្របសម្រាប់ឲ្យគាត់ឆ្លើយតបទៅលើសំណួរ ក៏ប៉ុន្តែពាក់ព័ន្ធទៅនឹងសំណួរទៅនឹងសំណួរនេះ គឺការធ្វើទារុណកម្មនៅមន្ទី ម-១៣... ក្នុងពេលអនាគតទៅវាអាចមានការចោទប្រកាន់ទៅលើគាត់ពីខាងសហព្រះរាជអាជ្ញា")។

[58] ប្រតិចារឹក ថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១២ អង្គជំនុំជម្រះ សំណុំរឿង ០០២ ឯកសារ E1/59.1 ទំព័រ ១០ បន្ទាត់ ៥-៧។

[59] សំណុំរឿង ០០២ ឯកសារ E200/4 អនុស្សរណៈពី ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង ផ្ញើជូនភាគីទាំងអស់ក្នុងសំណុំរឿង ០០១ ទាក់ទងនឹងការអនុញ្ញាតឲ្យប្រើប្រាស់ទម្រង់នៃលិខិតធានាអះអាងអំពីការមិនចោទប្រកាន់ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២ កថាខណ្ឌ ២។ *សូមមើលផងដែរ* សំណុំរឿង ០០២ ឯកសារ E200/3, អនុស្សរណៈ ពីចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង ផ្ញើជូនភាគីទាំងអស់ក្នុងសំណុំរឿង ០០២ ទាក់ទងនឹងការឆ្លើយតបរបស់អង្គជំនុំជម្រះ ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំការអនុញ្ញាតក្នុងការផ្តល់លិខិតធានាអះអាងអំពីការមិនចោទប្រកាន់ ដល់សាក្សីនានា (ឯកសារ E200), ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២ កថាខណ្ឌ២។

[60] ឯកសារ D308/3, ដីកាដំណោះស្រាយ (សំអាងហេតុ), ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ កថាខណ្ឌ ២៤។

D308/3/1/9

រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជាធានារក្សាសិទ្ធិប្រជាពលរដ្ឋរបស់ខ្លួនក្នុងការ "បរិហារ ប្តឹងផ្តល់ ឬទាមទារសំណងចំពោះការខូចខាតដែលបង្កឡើងដោយការរំលោភលើច្បាប់ណាមួយដោយស្ថាប័នរបស់រដ្ឋ"[61]។ រដ្ឋធម្មនុញ្ញនេះបានទទួលស្គាល់ប្រព័ន្ធតុលាការនេះថាជាប្រព័ន្ធតុលាការ "មានអំណាចឯករាជ្យ" ដែល "នឹង [...] ការពារសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ"[62]។ រដ្ឋធម្មនុញ្ញបានចែងថា ប្រព័ន្ធតុលាការ "នឹងពិចារណាលើគ្រប់ករណីផ្លូវច្បាប់ទាំងអស់ រួមទាំងករណីរដ្ឋបាលផងដែរ" ហើយថា "អំណាចនេះនឹងត្រូវប្រគល់ទៅឲ្យតុលាការកំពូល និងនៅក្នុងតុលាការទាំងអស់ លើគ្រប់វិស័យ និងគ្រប់ជាន់ថ្នាក់"[63] ។

30. លើសពីនេះទៀត បើទុកចោលតាមដំណើរ សំអាងហេតុនៃដីកាដំណោះស្រាយនឹងបង្ខំឲ្យរដ្ឋាភិបាលកម្ពុជាខកខានមិនបានបំពេញកាតព្វកិច្ចច្បាប់អន្តរជាតិរបស់ខ្លួន ដូចដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា[64]។ ជាការពិត ដូចដែលបានពិភាក្សាខាងលើ[65] ការលើកលែងទោស*ជាក់ស្តែង* ដ៏ទូលំទូលាយ ដែលប្រមើលមើលដោយដីកាដំណោះស្រាយ រំលោភលើច្បាប់អន្តរជាតិ និងកាតព្វកិច្ចសន្ធិសញ្ញាផ្ទាល់របស់ប្រទេសកម្ពុជា។ ដោយសារការបញ្ចូលកាតព្វកិច្ចសិទ្ធិមនុស្សនៅថ្នាក់ជាតិក្នុងស្រុក អនុលោមតាមរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា ការរំលោភបំពានទាំងនេះក៏ជាការរំលោភបំពានធ្ងន់ធ្ងរផងដែរលើច្បាប់របស់កម្ពុជា។

31. ដីកាដំណោះស្រាយមិនខ្វល់ ថាតើមូលដ្ឋានច្បាប់ជាតិនឹងអនុញ្ញាតឲ្យតុលាការកម្ពុជាសាមញ្ញដោះស្រាយឧក្រិដ្ឋកម្មសម័យខ្មែរក្រហម ឬក៏អត់នោះទេ។ មិនថា និងតាមអ្វីដែលមូលដ្ឋានច្បាប់ជាតិសំអាង តុលាការកម្ពុជាសាមញ្ញអាចកំណត់ថា ពួកគេអាចដោះស្រាយឧក្រិដ្ឋកម្មទាំងនេះបាន ឬអត់ គឺជាបញ្ហាមួយសម្រាប់ឲ្យតុលាការទាំងនេះដោះស្រាយដោយខ្លួនឯង និងស្ថិតនៅក្រៅ

---

61 រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (១៩៩៣ ការធ្វើវិសោធនកម្មនៅឆ្នាំ ២០០៨) មាត្រា ៣៩។

62 *សូមមើលខាងលើ* មាត្រា ១២៨។

63 *សូមមើលខាងលើ*។

64 រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (១៩៩៣ ការធ្វើវិសោធនកម្មនៅឆ្នាំ ២០០៨) មាត្រា ៣១ (ដែល "ទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដែលមានចែងនៅក្នុងធម្មនុញ្ញសហប្រជាជាតិ និងកតិកាសញ្ញា និងច្បាប់អនុសញ្ញា ដែលទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិកុមារ")។

65 *សូមមើល ផ្នែក ១១ ក២*។

D308/3/1/9

វិសាលភាពរបស់សហចៅក្រមស៊ើបអង្កេត[66]។ តុលាការកម្ពុជាអាចសម្រេចថា រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជាអនុញ្ញាតឲ្យ ឬសឹងតែតម្រូវឲ្យមានការប្រើប្រាស់ដោយផ្ទាល់នូវបទល្មើស ដែលត្រូវបានទទួលស្គាល់ ក្រោមច្បាប់ព្រហ្មទណ្ឌទំនៀមទម្លាប់អន្តរជាតិ សម្រាប់ឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហម។ ដូចគ្នានេះដែរ តុលាការទាំងនេះអាច ដោយធ្វើត្រាប់តាមតុលាការនៃបណ្ដាប្រទេសផ្សេងៗទៀតជាច្រើន[67] សម្រេចអនុញ្ញាតឲ្យមានការកាត់ទោសចំពោះឧក្រិដ្ឋកម្មដោយផ្អែកលើបទប្បញ្ញត្តិនានា (ដូចជាបទប្បញ្ញត្តិនៅក្នុងមាត្រា ១៨៣ ដល់ ១៩៨ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ ស្ដីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម) ដែលត្រូវបានអនុម័ត បន្ទាប់ពីមានការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ។ ឬ តុលាការទាំងនេះអាចអះអាងទទួលស្គាល់ការបកស្រាយផ្សេងមួយទៀត អំពីការពន្យារអាជ្ញាយុកាលនៃបណ្ដឹងអាជ្ញាដែលអាចធ្វើទៅបាន ក្រោមក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។ ទៅថ្ងៃមុខ កម្ពុជាសឹងតែអាចអនុម័តច្បាប់បន្ថែមដែលផ្ដល់យុត្តាធិការកាន់តែច្បាស់លាស់បន្ថែមទៀតដល់តុលាការជាតិរបស់ខ្លួន លើឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហម។ ប៉ុន្តែ ដូចដែលខ្លួនប្រកាន់ជំហរ ដីកាដំណោះស្រាយអះអាងថានឹងរារាំង តុលាការកម្ពុជាធម្មតាយ៉ាងច្បាស់លាស់ មិនឲ្យដោះស្រាយដោយខ្លួនឯង មិនថាតុលាការទាំងនេះអាចអនុវត្តយុត្តាធិការក្នុងរយៈពេលនេះបាន ឬអត់នោះទេ។ សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ស្នើសុំដោយក្ដីគោរពដល់អង្គបុរេ

---

[66] សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អវតក/កសចស (អបជ) ឯកសារ C5/45 សាលដីការបស់អង្គបុរេជំនុំជម្រះ ទៅលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្ដោះអាសន្នរបស់ជនត្រូវចោទ កាំង ហ្កេកអ៊ាវ ហៅ "ឌុច" ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០០៧ កថាខណ្ឌ ១៩ ("ក្នុងការអនុវត្តជាក់ស្ដែងនិងតាមផ្លូវច្បាប់ អ.វ.ត.ក គឺជាស្ថាប័នឯករាជ្យ ហើយដំណើរប្រតិបត្តិការរបស់ខ្លួនក៏ឯករាជ្យផងដែរ នៅក្នុងរចនាសម្ព័ន្ធតុលាការជាតិ *ដូច្នេះគ្មានសមត្ថកិច្ចវិនិច្ឆ័យលើចំណាត់ការរបស់ស្ថាប័នតុលាការឡើយ"។* (មានការបញ្ជាក់បន្ថែម)។

[67] *សូមមើល* ឧទាហរណ៍ អង់គ្លេស *តទល់នឹង* Sawoniuk សាលាឧទ្ធរណ៍ (កងឧក្រិដ្ឋកម្ម) (ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០០០) (មានការបញ្ជាក់ពីការកាត់ទោសពីរភាគបីនៃមនុស្សឃាតដែលបង្កើតបានជាឧក្រិដ្ឋកម្មសង្គ្រាមដែលបានធ្វើឡើងនៅឆ្នាំ ១៩៤២ ដែលនៅក្រោមច្បាប់ឧក្រិដ្ឋកម្មសង្គ្រាម ឆ្នាំ ១៩៩១)។ ប្រទេសបារាំង *រដ្ឋអាជ្ញា តទល់នឹង* Klaus Barbie, តុលាការកំពូលព្រហ្មទណ្ឌ (អង្គជំនុំជម្រះឧក្រិដ្ឋកម្ម) បណ្ដឹងឧទ្ធរណ៍លេខ 85-95166 (ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៨៥) (ដោយលើកឡើងថា តុលាការថ្នាក់ក្រោមអាចបន្តនីតិវិធីប្រឆាំងនឹងចុងចោទ ពីការអះអាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលធ្វើឡើងនៅឆ្នាំ ១៩៤៣-៤៤ ក្នុងចំណោមផ្សេងទៀត ច្បាប់ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៦៤ និងបទប្បញ្ញត្តិ ឆ្នាំ ១៩៨៣ ទៅលើក្រមនីតិវិធីព្រហ្មទណ្ឌបារាំង)។ ប្រទេសអ៊ីស្រាអែល *អគ្គរដ្ឋអាជ្ញា តទល់នឹង* Adolf Eichmann, អង្គជំនុំជម្រះតុលាការកំពូលប្រទេសអ៊ីស្រាអែល បណ្ដឹងឧក្រិដ្ឋកម្ម 336/61 (ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៦២) (ដោយលើកឡើងពីថាចុងចោទអាចនឹងរងពិរុទ្ធភាពពីច្បាប់អន្តរជាតិ ដោយផ្អែកលើច្បាប់ ឆ្នាំ ១៩៥០)។

D308/3/1/9

ជំនុំជម្រះថា ពុំគួរបណ្តែតបណ្តោយឲ្យសហចៅក្រមស៊ើបអង្កេតប៉ុនប៉ងដណ្តើមអធិបតេយ្យភាពរបស់ប្រទេសកម្ពុជា ដោយរំលោភលើច្បាប់អន្តរជាតិ និងច្បាប់កម្ពុជា លើបញ្ហាដ៏សំខាន់បែបនេះនោះទេ។

## សេចក្តីសន្និដ្ឋាន

32. ដូចដែលបានរៀបរាប់ពីខាងដើម សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមស្នើដោយក្តីគោរពដល់អង្គបុរេជំនុំជម្រះឲ្យដោះស្រាយសំអាងហេតុដែលមានការភាន់ច្រឡំ នៅក្នុងដីកាដំណោះស្រាយ នៅលើវិសាលភាពនៃយុត្តាធិការផ្តាច់មុខរបស់ អ.វ.ត.ក និងប្រកាសថា កម្រិតដែលតុលាការកម្ពុជាសាមញ្ញមានសមត្ថភាពលើផ្លូវច្បាប់ និងស្ថាប័នក្នុងការដោះស្រាយឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហម គឺជាបញ្ហាមួយដែលត្រូវប្រគល់ដល់តុលាការទាំងនោះឲ្យសម្រេចដោយខ្លួនឯង។

សូមដាក់ជូនដោយក្តីគោរព

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ៧ កញ្ញា ២០១៧ | សំ សុគង់<br>សហមេធាវីកម្ពុជាតំណាងដើមបណ្តឹងរដ្ឋប្បវេណី | ភ្នំពេញ<br>កម្ពុជា | |
| ៧ កញ្ញា ២០១៧ | Emmanuel JACOMY<br>សហមេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី | ហុងកុង<br>ចិន | |
| ៧ កញ្ញា ២០១៧ | Lyma NGUYEN<br>សហមេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី | ដាវីន<br>អូស្ត្រាលី | |